ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
លេខ.....០០៦.........សហវ.......

# សេចក្តីណែនាំ
# ស្តីពី
# ការដាក់ឱ្យអនុវត្តមុខងារលទ្ធកម្មពេញលេញ នៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) សម្រាប់ក្រសួង-ស្ថាប័ន និង អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ

មុខងារលទ្ធកម្មពេញលេញត្រូវបានដាក់ឱ្យអនុវត្តសាកល្បងដោយជោគជ័យនៅក្នុងឆ្នាំ ២០២១ ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, អង្គភាពលទ្ធកម្មនៃក្រសួងចំនួន ៣ គឺ៖ ១.ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ២.ក្រសួងព័ត៌មាន និង ៣.ក្រសួងកិច្ចការនារី ព្រមទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ២ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ទន្ទឹមនឹងនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក៏បានអភិវឌ្ឍនូវផ្នែកមួយចំនួនបន្ថែមទៀតនៅក្នុងមុខងារលទ្ធកម្មពេញលេញរួចរាល់ស្របតាមផែនការដែលបានគ្រោងទុក និង ត្រៀមរួចរាល់សម្រាប់ពង្រីកការប្រើប្រាស់ទៅកាន់ក្រសួង-ស្ថាប័នផ្សេងៗទៀត ។ មុខងារលទ្ធកម្មពេញលេញនេះ ចែកចេញជា៤ ផ្នែកគឺ៖ ទី១.ផ្នែកគ្រប់គ្រងបញ្ជីអ្នកដេញថ្លៃ, ទី២.ផ្នែកផែនការលទ្ធកម្ម, ទី៣.ផ្នែកគ្រប់គ្រងដំណើរការដេញថ្លៃ និង ទី៤.ផ្នែកគ្រប់គ្រងកិច្ចសន្យា ។

ស្របតាមផែនការសកម្មភាពរួមដំណាក់កាលទី ៣+២ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា និង ផែនការពង្រីកការអនុវត្តគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជំហានទី៣ (២០២១-២០២៥) មុខងារលទ្ធកម្មពេញលេញត្រូវដាក់ឱ្យប្រើប្រាស់នៅគ្រប់ក្រសួង-ស្ថាប័នទាំងអស់ រួមទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញទាំងអស់ដែលបាន និង កំពុងប្រើប្រាស់ប្រព័ន្ធ FMIS ចាប់ពីឆ្នាំ ២០២២ នេះតទៅ លើកលែងតែអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ១០ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលទើបតែបានប្រើប្រាស់ប្រព័ន្ធ FMIS ក្នុងឆ្នាំ ២០២២ នេះរួមមាន៖ ១.អគ្គនាយកដ្ឋានគោលនយោបាយ, ២.អគ្គនាយកដ្ឋានថវិកា, ៣.អគ្គនាយដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ, ៤.អគ្គនាយដ្ឋានលទ្ធកម្មសាធារណៈ, ៥.អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ, ៦.អគ្គាធិការដ្ឋាន, ៧.អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង, ៨.អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍, ៩.អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល និង ១០.វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំដល់ក្រសួង-ស្ថាប័ន និង អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ អំពីការអនុវត្តមុខងារលទ្ធកម្មពេញលេញនៃប្រព័ន្ធ FMIS ដូចតទៅ៖

## ១. ផ្នែកការគ្រប់គ្រងបញ្ជីអ្នកដេញថ្លៃ

១.១.អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវប្រើប្រាស់ផ្នែកគ្រប់គ្រងបញ្ជីអ្នកដេញថ្លៃ ដើម្បីបង្កើតប្រតិបត្តិការ ពិនិត្យ ផ្ទៀងផ្ទាត់ និង អនុម័ត សម្រាប់ប្រតិបត្តិការបង្កើតឈ្មោះអ្នកដេញថ្លៃថ្មី និង ប្រតិបត្តិការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកដេញថ្លៃដែលបានចុះបញ្ជីរួចហើយ ។

១.២. អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលបានសិទ្ធិបង្កើត ឬ ធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកដេញថ្លៃ ត្រូវ បង្កើត ឬ ធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់អ្នកដេញថ្លៃនៅក្នុងប្រព័ន្ធ នៅពេលមានការស្នើសុំចុះឈ្មោះអ្នកដេញថ្លៃថ្មី ឬ នៅពេលមានការស្នើសុំធ្វើបច្ចុប្បន្នភាពព័ត៌មានពីអ្នកដេញថ្លៃដែលបានចុះបញ្ជីរួច ។ នៅពេលដែលអ្នកប្រើប្រាស់ប្រព័ន្ធពិនិត្យ និង ផ្ទៀងផ្ទាត់ទិន្នន័យឃើញថាមានភាពត្រឹមត្រូវហើយ អ្នកប្រើប្រាស់ប្រព័ន្ធត្រូវបញ្ជូនបន្តទៅកាន់អ្នកមានសិទ្ធិអនុម័តលើការស្នើសុំចុះឈ្មោះអ្នកដេញថ្លៃថ្មី ឬ អ្នកស្នើសុំធ្វើបច្ចុប្បន្នភាពព័ត៌មានពីអ្នកដេញថ្លៃដែលបានចុះបញ្ជីរួច ។ បន្ទាប់ពីទទួលបានការអនុម័តរួចនៅក្នុងប្រព័ន្ធ អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិបង្កើតត្រូវធ្វើការបោះពុម្ពវិញ្ញាបនបត្រអ្នកដេញថ្លៃចេញពីប្រព័ន្ធ ។

១.៣. ក្រោយពីទទួលបានការឯកភាពជាផ្លូវការពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការស្នើសុំចុះឈ្មោះអ្នកដេញថ្លៃថ្មី ឬ ការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកដេញថ្លៃដែលបានចុះបញ្ជីរួចហើយ អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិពិនិត្យ និង ផ្ទៀងផ្ទាត់ និង អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិអនុម័ត ត្រូវធ្វើការពិនិត្យឱ្យបានហ្មត់ចត់មុនអនុម័តលើទិន្នន័យរបស់អ្នកដេញថ្លៃដែលបានបង្កើត ឬ ធ្វើបច្ចុប្បន្នភាពរួចក្នុងចំណុច ១.២ ខាងលើ តាមតួនាទីរៀងខ្លួននៅក្នុងប្រព័ន្ធ ។

## ២. ផ្នែកការរៀបចំផែនការលទ្ធកម្ម

២.១. អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនីមួយៗ, អង្គភាពលទ្ធកម្មនៃក្រសួង-ស្ថាប័ននីមួយៗ និង នៅអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវប្រើប្រាស់ផ្នែកផែនការលទ្ធកម្មនៅក្នុងប្រព័ន្ធដើម្បីបង្កើតប្រតិបត្តិការ ពិនិត្យ ផ្ទៀងផ្ទាត់ និង អនុម័ត សម្រាប់ប្រតិបត្តិការបង្កើតផែនការលទ្ធកម្មប្រចាំឆ្នាំ និង ប្រតិបត្តិការកែតម្រូវផែនការលទ្ធកម្ម ។

២.២. ចំពោះផែនការលទ្ធកម្មរបស់អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនីមួយៗ បន្ទាប់ពីបានរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំរួចរាល់ អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិបង្កើតប្រតិបត្តិការ និង អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិអនុម័តប្រតិបត្តិការរបស់អង្គភាពថវិកាអាណាប័កនីមួយៗ ត្រូវបង្កើតប្រតិបត្តិការផែនការលទ្ធកម្មប្រចាំឆ្នាំ និង ធ្វើការពិនិត្យអនុម័តតាមតួនាទីរៀងខ្លួននៅក្នុងប្រព័ន្ធ រួចបញ្ជូនប្រតិបត្តិការបន្ត ។

២.៣. ចំពោះផែនការលទ្ធកម្មរបស់អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនីមួយៗ បន្ទាប់ពីទទួលបានឯកសារ និង ប្រតិបត្តិការនៅក្នុងប្រព័ន្ធអំពីផែនការលទ្ធកម្មប្រចាំឆ្នាំរបស់អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនីមួយៗ អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិត្រួតពិនិត្យ និង អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិអនុម័តប្រតិបត្តិការរបស់អង្គភាពលទ្ធកម្មនៃក្រសួងសាមី ត្រូវបន្តធ្វើការពិនិត្យប្រតិបត្តិការដោយធ្វើការផ្ទៀតផ្ទាត់ជាមួយឧបសម្ព័ន្ធនៃផែនការលទ្ធកម្មនោះឱ្យបានហ្មត់ចត់ រួចធ្វើការអនុម័តតាមតួនាទីរៀងខ្លួននៅក្នុងប្រព័ន្ធ បន្ទាប់មកបញ្ជូនប្រតិបត្តិការបន្ត ។

២.៤. ករណីជាផែនការលទ្ធកម្មប្រចាំឆ្នាំ និង ឧបសម្ព័ន្ធផែនការលទ្ធកម្មផ្សេងទៀតក្នុងក្របខណ្ឌក្រសួង-ស្ថាប័ននីមួយៗដូចមានរៀបរាប់ខាងលើ បន្ទាប់ពីទទួលបាននូវឯកសារផែនការលទ្ធកម្មប្រចាំឆ្នាំគ្រប់គ្រាន់ អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិបង្កើតប្រតិបត្តិការ និង អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិអនុម័តប្រតិបត្តិការរបស់អង្គភាពលទ្ធកម្មនៃក្រសួង-ស្ថាប័ននីមួយៗ ត្រូវបង្កើតប្រតិបត្តិការផែនការលទ្ធកម្មប្រចាំឆ្នាំសម្រាប់ក្រសួង-ស្ថាប័ននីមួយៗ (រួមទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញទាំងថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន) ផ្អែកលើឧបសម្ព័ន្ធផែនការលទ្ធកម្ម រួចធ្វើការពិនិត្យលើប្រតិបត្តិការផែនការលទ្ធកម្មនោះឱ្យបានហ្មត់ចត់មុនធ្វើការអនុម័តតាមតួនាទីរៀងខ្លួននៅក្នុងប្រព័ន្ធ រួចបញ្ជូនប្រតិបត្តិការបន្ត ។

២.៥. បន្ទាប់ពីទទួលបាននូវឯកសារផ្លូវការ និង ប្រតិបត្តិការនៅក្នុងប្រព័ន្ធសម្រាប់ផែនការលទ្ធកម្មប្រចាំឆ្នាំ និង ឧបសម្ព័ន្ធរបស់ក្រសួង-ស្ថាប័ននីមួយៗ រួមទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនីមួយៗ អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិត្រួតពិនិត្យ និង ផ្ទៀងផ្ទាត់ និង អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិអនុម័ត របស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវធ្វើការពិនិត្យ និងផ្ទៀងផ្ទាត់ លើប្រតិបត្តិការផែនការលទ្ធកម្មនោះឱ្យបានហ្មត់ចត់ មុននឹងអនុម័តបញ្ចប់ចុងក្រោយ តាមតួនាទីរៀងខ្លួននៅក្នុងប្រព័ន្ធ ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមិនអនុញ្ញាតឱ្យផ្តល់ធានាចំណាយឡើយ ចំពោះគម្រោងចំណាយណាដែលមិនបានកត់ត្រានៅក្នុងផែនការលទ្ធកម្ម ។

២.៦. សម្រាប់ករណីផែនការលទ្ធកម្មកែតម្រូវ អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិកែតម្រូវ, អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិត្រួតពិនិត្យ និង អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិអនុម័ត លើប្រតិបត្តិការកែតម្រូវផែនការលទ្ធកម្មនៅក្នុងប្រព័ន្ធ នៅអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ, អង្គភាពលទ្ធកម្មនៃក្រសួង-ស្ថាប័ននីមួយៗ និង នៅអគ្គនាយកដ្ឋានលទ្ធកម្មសារធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តដូចគ្នានឹងការអនុវត្តការបង្កើតផែនការលទ្ធកម្មក្នុងចំណុច ២.២, ២.៣, ២.៤ និង ២.៥ ខាងលើ ។

## ៣. ផ្នែកការគ្រប់គ្រងដំណើរការដេញថ្លៃ

៣.១. ក្រុមលទ្ធកម្មនៃអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនីមួយៗ, អង្គភាពលទ្ធកម្មនៃក្រសួង-ស្ថាប័ននីមួយៗ និង អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវប្រើប្រាស់ផ្នែកគ្រប់គ្រងដំណើរការដេញថ្លៃនៅក្នុងប្រព័ន្ធ FMIS ដើម្បីបង្កើតប្រតិបត្តិការ ពិនិត្យ ផ្ទៀងផ្ទាត់ និង អនុម័ត សម្រាប់ប្រតិបត្តិការកម្មវិធីដេញថ្លៃ, ប្រតិបត្តិការការចូលរួមដេញថ្លៃ, ប្រតិបត្តិការការវាយតម្លៃឯកសារដេញថ្លៃឬសំណើដេញថ្លៃ និង ប្រតិបត្តិការការជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យា ។

៣.២. អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិបង្កើតប្រតិបត្តិការក្នុងផ្នែកដំណើរការដេញថ្លៃ របស់ក្រុមលទ្ធកម្មនៃអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនីមួយៗ និង អង្គភាពលទ្ធកម្មនៃក្រសួង-ស្ថាប័ននីមួយៗ ត្រូវបង្កើតប្រតិបត្តិការកម្មវិធីដេញថ្លៃ, ប្រតិបត្តិការការចូលរួមដេញថ្លៃ, ប្រតិបត្តិការវាយតម្លៃឯកសារដេញថ្លៃឬសំណើដេញថ្លៃ និង ប្រតិបត្តិការការជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យានៅក្នុងប្រព័ន្ធ បន្ទាប់ពីបញ្ចប់ដំណាក់កាលនីមួយៗនៃដំណើរការដេញថ្លៃ ។ សម្រាប់ប្រតិបត្តិការកម្មវិធីដេញថ្លៃ និង ប្រតិបត្តិការវាយតម្លៃឯកសារដេញថ្លៃឬសំណើដេញថ្លៃ អ្នកប្រើប្រាស់ប្រព័ន្ធត្រូវធ្វើការបញ្ជូនប្រតិបត្តិការបន្ត ។

៣.៣. បន្ទាប់ពីទទួលបាននូវឯកសារផ្លូវការ និង ប្រតិបត្តិការកម្មវិធីដេញថ្លៃ ឬ ប្រតិបត្តិការវាយតម្លៃឯកសារដេញថ្លៃឬសំណើដេញថ្លៃនៅក្នុងប្រព័ន្ធ, អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិអនុម័តរបស់ក្រុមលទ្ធកម្មនៃអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនីមួយៗ និង អង្គភាពលទ្ធកម្មនៃក្រសួង-ស្ថាប័ននីមួយៗ ត្រូវបន្តធ្វើការពិនិត្យផ្ទៀងផ្ទាត់ឱ្យបានហ្មត់ចត់ និង អនុម័តបញ្ចប់ប្រតិបត្តិការនៅក្នុងប្រព័ន្ធសម្រាប់ករណីកិច្ចលទ្ធកម្មក្រោមកម្រិតទឹកប្រាក់សិទ្ធិសម្រេច ។ ដោយឡែក សម្រាប់ករណីកិច្ចលទ្ធកម្មលើសសិទ្ធិសម្រេចឬកិច្ចលទ្ធកម្មដោយឡែក អ្នកប្រើប្រាស់ប្រព័ន្ធត្រូវបញ្ជូនប្រតិបត្តិការបន្ត បន្ទាប់ពីបានអនុម័តរួច ។

៣.៤. សម្រាប់កិច្ចលទ្ធកម្មលើសសិទ្ធិសម្រេច និង កិច្ចលទ្ធកម្មដោយឡែក, បន្ទាប់ពីទទួលបានឯកសារផ្លូវការ និង ប្រតិបត្តិការកម្មវិធីដេញថ្លៃ ឬ ប្រតិបត្តិការការវាយតម្លៃឯកសារដេញថ្លៃឬសំណើដេញថ្លៃនៅក្នុងប្រព័ន្ធ, អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិអនុម័តរបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបន្តធ្វើការពិនិត្យផ្ទៀងផ្ទាត់ឱ្យបានហ្មត់ចត់ និង ធ្វើការអនុម័តបញ្ចប់នៅក្នុងប្រព័ន្ធ បន្ទាប់ពីពិនិត្យឃើញថាត្រឹមត្រូវ ។

## ៤. ផ្នែកការគ្រប់គ្រងកិច្ចសន្យា

៤.១. ក្រុមលទ្ធកម្មនៃអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនីមួយៗ, អង្គភាពលទ្ធកម្មនៃក្រសួង-ស្ថាប័ននីមួយៗ និង អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវប្រើប្រាស់ផ្នែកគ្រប់គ្រងកិច្ចសន្យា ដើម្បីបង្កើតប្រតិបត្តិការ ពិនិត្យ ផ្ទៀងផ្ទាត់ និង អនុម័ត សម្រាប់ប្រតិបត្តិការការគ្រប់គ្រងកិច្ចសន្យាលទ្ធកម្មសាធារណៈ, ការកែប្រែកិច្ចសន្យា (តម្លៃ, រយៈពេលអនុវត្ត, និងលក្ខខណ្ឌនៃកិច្ចសន្យា), ការបញ្ជាទិញ និង របាយការណ៍វាយតម្លៃវឌ្ឍនភាពការងារ ឬ វិញ្ញាបនបត្របញ្ចប់ការងារ ឬ វិញ្ញាបនបត្របញ្ចប់សុពលភាពការងារសំណង់ ។

៤.២. បន្ទាប់ពីប្រកាសអ្នកដេញថ្លៃឈ្នះ និង ចុះកិច្ចសន្យារួចរាល់ដោយក្រសួង-ស្ថាប័នសាមីជាមួយនឹងអ្នកដេញថ្លៃឈ្នះ, អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិបង្កើតប្រតិបត្តិការ និង អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិអនុម័តប្រតិបត្តិការរបស់ក្រុមលទ្ធកម្មនៃអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនីមួយៗ និង អង្គភាពលទ្ធកម្មនៃក្រសួង-ស្ថាប័ន នីមួយៗ ត្រូវបង្កើតប្រតិបត្តិការគ្រប់គ្រងកិច្ចសន្យាលទ្ធកម្មសាធារណៈ និង ធ្វើការពិនិត្យឱ្យបានហ្មត់ចត់មុនធ្វើការអនុម័តប្រតិបត្តិការគ្រប់គ្រងកិច្ចសន្យាលទ្ធកម្មសាធារណៈនោះតាមតួនាទីរៀងខ្លួននៅក្នុងប្រព័ន្ធសម្រាប់ករណីកិច្ចសន្យាក្រោមសិទ្ធិសម្រេច ។ ដោយឡែក ករណីកិច្ចលទ្ធកម្មលើសសិទ្ធិសម្រេច, កិច្ចលទ្ធកម្មដោយឡែក (ការចុះកិច្ចសន្យាផ្ទាល់, ការចុះកិច្ចសន្យាជាមួយអង្គភាពជំនាញនៃស្ថាប័នអនុវត្តលទ្ធកម្ម, លទ្ធកម្មភាគកម្មសហគមន៍) អ្នកប្រើប្រាស់ប្រព័ន្ធត្រូវបញ្ជូនប្រតិបត្តិការបន្តមកកាន់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

៤.៣. ករណីកិច្ចលទ្ធកម្មលើសសិទ្ធិសម្រេច និង កិច្ចលទ្ធកម្មដោយឡែក បន្ទាប់ពីទទួលបានឯកសារកិច្ចសន្យាជាផ្លូវការ និង ប្រតិបត្តិការនៅក្នុងប្រព័ន្ធ, អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិត្រួតពិនិត្យ និង ផ្ទៀងផ្ទាត់ និង អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិអនុម័តរបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបន្តត្រួតពិនិត្យ និង ផ្ទៀងផ្ទាត់ឱ្យបានហ្មត់ចត់ និង ធ្វើការអនុម័តលើប្រតិបត្តិការនៃការគ្រប់គ្រងកិច្ចសន្យាតាមតួនាទីរៀងខ្លួននៅក្នុងប្រព័ន្ធ ដើម្បីបញ្ចប់ប្រតិបត្តិការកិច្ចលទ្ធកម្មលើសសិទ្ធិសម្រេច និង កិច្ចលទ្ធកម្មដោយឡែក ។

៤.៤. បន្ទាប់ពីទទួលបានឯកសារលិខិតប្រគល់ទទួល និង ឯកសារពាក់ព័ន្ធផ្សេងៗ, អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិបង្កើតប្រតិបត្តិការបញ្ជាទិញរបស់ក្រុមលទ្ធកម្ម នៃអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនីមួយៗ អង្គភាពលទ្ធកម្មនៃក្រសួង-ស្ថាប័ននីមួយៗ ត្រូវបង្កើតប្រតិបត្តិការបញ្ជាទិញ និង ការប្រគល់ទទួលដើម្បីបញ្ចប់ប្រតិបត្តិការក្នុងប្រព័ន្ធករណីកិច្ចលទ្ធកម្មក្រោមសិទ្ធិសម្រេច និង បញ្ជូនមកអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីអនុម័តករណីកិច្ចលទ្ធកម្មលើសសិទ្ធិសម្រេច និង កិច្ចលទ្ធកម្មដោយឡែក ។

៤.៥. សម្រាប់របាយការណ៍វាយតម្លៃវឌ្ឍនភាពការងារ ឬ វិញ្ញាបនបត្របញ្ចប់ការងារ ឬ វិញ្ញាបនបត្របញ្ចប់សុពលភាពការងារសំណង់, អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិបោះពុម្ពរបស់ក្រុមលទ្ធកម្មនៃអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនីមួយៗ, អង្គភាពលទ្ធកម្មនៃក្រសួង-ស្ថាប័ននីមួយៗ និង អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចធ្វើការបោះពុម្ពរបាយការណ៍វាយតម្លៃវឌ្ឍនភាពការងារ ឬ វិញ្ញាបនបត្របញ្ចប់ការងារ ឬ វិញ្ញាបនបត្របញ្ចប់សុពលភាពការងារសំណង់ចេញពីប្រព័ន្ធបានតាមរយៈការវាយតម្លៃពីក្រុមការងារវាយតម្លៃវឌ្ឍនភាពគម្រោង ឬ គណៈកម្មការចំពោះកិច្ចការវាយតម្លៃគម្រោង ។

*ករណីក្រសួង-ស្ថាប័ន និង អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ មិនបានអនុវត្តប្រតិបត្តិការកិច្ចលទ្ធកម្មនៅក្នុងមុខងារលទ្ធកម្មពេញលេញនោះទេ គឺអាចប្រឈមនឹងការបញ្ជូនត្រលប់វិញដោយអគ្គនាយកដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់កិច្ចប្រតិបត្តិការចំណាយថវិកា ដើម្បីអនុវត្តប្រតិបត្តិការកិច្ចលទ្ធកម្មឱ្យបានគ្រប់ជ្រុងជ្រោយក្នុងមុខងារលទ្ធកម្មពេញលេញ មុននឹងធ្វើប្រតិបត្តិការស្នើសុំទូទាត់ ។*

ក្រសួង-ស្ថាប័ន, អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ, អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, អគ្គនាយកដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង អង្គភាពពាក់ព័ន្ធនានាត្រូវទទួលបន្ទុកអនុវត្តតាមសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*ថ្ងៃសុក្រ ១៣កើត ខែពិសាខ ឆ្នាំ ខាល ចត្វាស័ក ព.ស.២៥៦៥*

*រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែឧសភា ឆ្នាំ ២០២២*

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**<u>កន្លែងទទួល៖</u>**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី

“ដើម្បីជូនជ្រាប”

-ក្រសួង-ស្ថាប័ន

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-អគ្គនាយកដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

“ដើម្បីអនុវត្ត”

-ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃសេចក្តីណែនាំលេខ.០០៦.សហវ..... ចុះថ្ងៃទី.១៣ ខែ ឧសភា ឆ្នាំ២០២២

*ស្តីពី ការដាក់ឱ្យអនុវត្តមុខងារលទ្ធកម្មពេញលេញ នៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ក្របខណ្ឌក្រសួង-ស្ថាប័ន និង អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ*

## វិហ្វូវនៃការប្រើប្រាស់មុខងារលទ្ធកម្មពេញលេញនៃប្រព័ន្ធ FMIS

### ១. *វិហ្វូវក្នុងផ្នែកគ្រប់គ្រងបញ្ជីឈ្មោះអ្នកដេញថ្លៃ*




### ២. *វិហ្វូវក្នុងផ្នែកផែនការលទ្ធកម្ម*

### ២.១. *ករណីផែនការលទ្ធកម្មដែលបង្កើតក្នុងប្រព័ន្ធដោយអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ*



### ២.២. *ករណីជាផែនការលទ្ធកម្មក្នុងក្របខណ្ឌក្រសួងនីមួយៗ (លើកលែងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញដែលបង្កើតដោយខ្លួនឯង)*




## ៣. *ផ្នែកគ្រប់គ្រងដំណើរការដេញថ្លៃ*

### ៣.១. *ប្រតិបត្តិការកម្មវិធីដេញថ្លៃក្រោមសិទ្ធិសម្រេច*



## ៣.២. ប្រតិបត្តិការវាយតម្លៃការដេញថ្លៃក្រោមសិទ្ធិសម្រេច




## ៣.៣. ប្រតិបត្តិការកម្មវិធីដេញថ្លៃលើសសិទ្ធិសម្រេច



### ៣.៤. ប្រតិបត្តិការវាយតម្លៃការដេញថ្លៃលើសសិទ្ធិសម្រេច




## ៤. ផ្នែកគ្រប់គ្រងកិច្ចសន្យា

### ៤.១. ប្រតិបត្តិការកិច្ចសន្យាក្រោមសិទ្ធិសម្រេច



## ៤.២. ប្រតិបត្តិការកិច្ចសន្យាដេញថ្លៃលើសសិទ្ធិសម្រេច




| | | |
|---|---|---|
| វិហ្វរក្រៅប្រព័ន្ធ | វិហ្វរក្នុងប្រព័ន្ធ FMIS | កសហវ = ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |